# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**អគ្គនាយកដ្ឋានអាស៊ាន**

សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និង៤៥

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាន អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និងលើកទី៤៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ក្រោមមូលបទ "**អាស៊ាន៖ ការពង្រឹងការតភ្ជាប់ និងភាពធន់**" ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅទីក្រុងវៀងចន្ទន៍ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤។

### កិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និងលើកទី៤៥

ក្នុងកិច្ចប្រជុំពេញអង្គ ប្រមុខដឹកនាំបានពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែងរួមរបស់អាស៊ាន ក្នុងការជំរុញវឌ្ឍនភាពនៃការកសាងសហគមន៍អាស៊ាន និងបានផ្លាស់ប្តូរទស្សនៈស្តីពីទិសដៅអនាគតនៃទំនាក់ទំនងជាមួយដៃគូខាងក្រៅអាស៊ាន។ ប្រមុខដឹកនាំបានថ្លែងកោតសរសើរចំពោះការងាររបស់ក្រុមការងារជាន់ខ្ពស់សម្រាប់ចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ និងភាគីពាក់ព័ន្ធនានា ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីអនុវត្តចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ និងទន្ទឹងរង់ចាំការអនុម័តឯកសារសំខាន់ៗទាំងនេះ នៅពេលដែលម៉ាឡេស៊ីធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២៥។ ក្នុងន័យនេះ ប្រមុខដឹកនាំបានអនុម័តសេចក្តីប្រកាសរបស់ប្រមុខដឹកនាំអាស៊ាន ស្តីពីការអភិវឌ្ឍផែនការយុទ្ធសាស្ត្រដើម្បីអនុវត្តចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥។

ពាក់ព័ន្ធទំនាក់ទំនងជាមួយដៃគូខាងក្រៅអាស៊ាន ប្រមុខដឹកនាំបានអះអាងសាជាថ្មីអំពីសារសំខាន់នៃការលើកកម្ពស់ និងពង្រឹងមជ្ឈភាពនិងឯកភាពអាស៊ាន នៅក្នុងបរិបទនិម្មាបនកម្មតំបន់ដែលកំពុងតែវិវត្ត និងទិដ្ឋភាពភូមិសាស្ត្រនយោបាយដែលមិនច្បាស់លាស់។ ប្រមុខដឹកនាំក៏បានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនាអាស៊ាន និង ដៃគូខាងក្រៅផ្សេងទៀត លើបញ្ហាដែលជាផលប្រយោជន៍ និងកង្វល់រួម ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុង និងក្រៅតំបន់។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មី អំពីការគាំទ្រយ៉ាងពេញទំហឹងរបស់កម្ពុជា ចំពោះអាទិភាពរបស់ឡាវដែលជាប្រធានអាស៊ាន ជាពិសេសការពង្រឹងការតភ្ជាប់ និងភាពធន់ដែលឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅជាមួយនឹងសេចក្តីប្រាថ្នា និងចក្ខុវិស័យរួមរបស់អាស៊ាន ដើម្បីសម្រេចបាននូវតំបន់អាស៊ីអាគ្នេយ៍មួយ ដែលរឹងមាំ ប្រកបដោយវិបុលភាព និងមានភាពសមាហរណកម្ម។ **សម្តេចធិបតី** បានសង្កត់ធ្ងន់ថា ចំពោះការប្រឈមមុខនឹងភាពស្មុគស្មាញ និងភាពមិនច្បាស់លាស់ដែលកាន់តែខ្លាំងឡើងដោយ បញ្ហាសន្តិសុខប្រពៃណី និងមិនប្រពៃណី ការឆ្លើយតបរួមរបស់អាស៊ានត្រូវតែមានភាពបុរេសកម្ម ការប្រមើលមើលគិតទុកជាមុន និងមានលក្ខណៈជាយុទ្ធសាស្ត្រ ដើម្បីត្រៀមខ្លួនប្រកបដោយភាពធន់ទៅនឹងអនាគត។

**សម្តេចធិបតី** បានសង្កត់ធ្ងន់ថា អាស៊ានគួរតែរក្សាការប្តេជ្ញាចិត្តចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដែលមានលក្ខណៈសេរី បើកចំហ បរិយាប័ន្ន យុត្តិធម៌ និងតម្លាភាព ទន្ទឹមនឹងនោះក៏បានអំពាវនាវឱ្យអាស៊ានពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មក្នុងចំណោមប្រទេសសមាជិក និងជាមួយដៃគូអាស៊ាន។ ដើម្បីរក្សា អាស៊ានជាកម្លាំងចលករសម្រាប់វិបុលភាពពិភពលោក **សម្តេចធិបតី** បានគូសបញ្ជាក់ថា អាស៊ានគួរតែប្រើប្រាស់សក្តានុពលដ៏ធំនៃវិស័យដែលកំពុងរីកចម្រើន ដូចជាសេដ្ឋកិច្ចឌីជីថល អន្តរកាលបៃតង សេដ្ឋកិច្ចពណ៌ខៀវ និងខ្សែច្រវាក់ផ្គត់ផ្គង់ប្រកបដោយភាពធន់ដើម្បីបន្តទទួលបាននូវកំណើនខ្ពស់ប្រកបដោយ និរន្តរភាព។

ឆ្លៀតក្នុងឱកាសនោះ **សម្តេចធិបតី** ក៏បានបញ្ជាក់ជាថ្មីថាអំពីការគាំទ្ររបស់កម្ពុជាឱ្យទីម័រខាងកើតក្លាយជាសមាជិកពេញសិទ្ធិរបស់អាស៊ានឱ្យបានឆាប់បំផុត និងបានបញ្ជាក់ការគាំទ្រចំពោះវិធីសាស្ត្រជាក់ស្តែង ឬប្រកបដោយភាពច្នៃប្រឌិតណាមួយដែលអាចជួយសម្រេចបាននូវគោលដៅនេះ។ **សម្តេចធិបតី** បានស្វាគមន៍ការចាប់អារម្មណ៍កាន់តែខ្លាំងឡើងពីប្រទេសក្រៅតំបន់ចំពោះការចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) និងបានរំលឹកសាជាថ្មីអំពីសារសំខាន់នៃការស្វាគមន៍ដៃគូទាំងឡាយណាដែលចង់បង្កើតទំនាក់ទំនងជាមួយអាស៊ានដោយផ្អែកលើគោលការណ៍នៃការគោរពគ្នា ការទុកចិត្តគ្នា និងការផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក។

នៅក្នុងសម័យប្រជុំចង្អៀត ប្រមុខដឹកនាំបានពិភាក្សាអំពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុចស្តីពីមីយ៉ាន់ម៉ា និងបានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិដែលជាផលប្រយោជន៍ និងកង្វល់រួម។

**ជំនួបនានារបស់ថ្នាក់ដឹកនាំអាស៊ាន**

នៅក្នុងជំនួបរវាងប្រមុខដឹកនាំអាស៊ាន ជាមួយតំណាងអន្តរសភាអាស៊ាន (AIPA) **សម្តេចធិបតី** បានគូសបញ្ជាក់អំពីសារសំខាន់ក្នុងការលើកកម្ពស់ និងថែរក្សានូវសន្តិភាពដែលមានស្រាប់ និងសន្តិសហវិជ្ជមានរវាងរដ្ឋ នៅខណៈដែលមានការងើបឡើងនូវជម្លោះហិង្សានៅតាមតំបន់នានានៃពិភពលោក និងនិន្នាការកើនឡើងនូវនយោបាយជ្រុលនិយម និងប្រជានិយម។ **សម្តេចធិបតី** ក៏បានសង្កត់ធ្ងន់លើភាពចាំបាច់សម្រាប់រដ្ឋាភិបាល និងស្ថាប័នសភា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ឧស្សាហកម្មដែលកំពុងលេចឡើងថ្មី ដែលរួមមាន៖ សេដ្ឋកិច្ចឌីជីថល និងអន្តរកាលបៃតង និងការដាក់ចេញនូវក្របខណ្ឌច្បាប់ ប្រកបដោយប្រសិទ្ធភាព ដែលអាចជួយតំបន់យើងឱ្យទាញផលពីសក្តានុពលដ៏អស្ចារ្យ នៃវិស័យទាំងនេះ។

នៅក្នុងជំនួបរវាងប្រមុខដឹកនាំអាស៊ាន ជាមួយក្រុមប្រឹក្សាធុរកិច្ចអាស៊ាន **សម្តេចធិបតី** បានសង្កត់ធ្ងន់លើសារសំខាន់របស់ការបន្តធ្វើកិច្ចសហការរវាងវិស័យសាធារណៈ និងវិស័យឯកជនរបស់អាស៊ាន ដើម្បីគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅខណៈដែលលម្ហូវិកាមានកម្រិត និងលើកទឹកចិត្តឱ្យមានកិច្ចសហការបន្ថែមទៀតនៅក្នុងផ្នែកតភ្ជាប់ក្នុងតំបន់ បរិវត្តកម្មឌីជីថល និងអន្តរកាលបៃតង។ **សម្តេចធិបតី** បានជម្រាបជូនអង្គប្រជុំថា កម្ពុជាទើបតែបានដាក់ចេញនូវផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្ម នៅដើមឆ្នាំ២០២៤ និងបានស្នើវិស័យឯកជនពិចារណាអំពីឱកាសដ៏គួរឱ្យទាក់ទាញនេះ។ **សម្តេចធិបតី** ក៏បានគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់វិស័យឯកជន ក្នុងការរួមចំណែកដល់ការរីកចម្រើនដ៏ឆាប់រហ័សនៃសេដ្ឋកិច្ច និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនក្នុងតំបន់៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

General Department of ASEAN

PRESS RELEASE

## Outcomes of the 44th and 45th ASEAN Summits

**Samdech Moha Borvor Thipadei HUN Manet**, Prime Minister of the Kingdom of Cambodia, attended the 44th and 45th ASEAN Summits and Related Summits, under the theme "**ASEAN: Enhancing Connectivity and Resilience**", chaired by **His Excellency Dr. Sonexay SIPHANDONE**, Prime Minister of the Lao People's Democratic Republic (Lao PDR), in Vientiane on 9 October 2024.

### 1. 44th and 45th ASEAN Summits

During the Plenary Session, the Leaders discussed ASEAN's concerted efforts in advancing the ASEAN Community building process and exchanged views on future direction of ASEAN external relations. The Leaders commended the works of the High-Level Task Force on ASEAN Community Vision 2045 (HLTF-ACV) and other relevant stakeholders in developing the Strategic Plans to implement the ASEAN Community Vision 2045 and looked forward to the adoption of these milestone documents during Malaysia's ASEAN Chairmanship in 2025. In this regard, the Leaders adopted the ASEAN Leaders' Declaration on the Development of Strategic Plans to Implement the ASEAN Community Vision 2045.

On ASEAN external relations, the Leaders' reaffirmed the importance of upholding and strengthening ASEAN centrality and unity in the context of the evolving regional architecture and the precarious geopolitical landscape. The Leaders also stressed the need to further enhance cooperation with ASEAN Dialogue Partners and

Address : N° 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : [illegible]
Fax : [illegible] 216 141, [illegible] 41
Email : [illegible]

other external partners on issues of common interest and concern to promote peace, stability, and prosperity in the region and beyond.

**Samdech Thipadei Prime Minister** reaffirmed Cambodia's full support for the priorities of Lao PDR as the ASEAN Chair, especially as enhancing connectivity and resilience resonates deeply with ASEAN's shared aspirations and collective vision for a robust, prosperous and integrated Southeast Asia. **Samdech Thipadei** emphasised that in the face of growing geopolitical complexity and uncertainty, exacerbated by both traditional and non-traditional security issues, ASEAN's shared responses must be proactive, anticipatory and strategic so that the region will be future-proof and future-ready.

**Samdech Thipadei** stressed that ASEAN should remain committed to a multilateral trading system that is free, open, inclusive, fair and transparent while also calling on ASEAN to expand trade cooperation among itself and with partners. For ASEAN to remain a driving force for global prosperity, **Samdech Thipadei** highlighted that ASEAN should leverage on the huge potential of emerging sectors, including digital economy, green transition, blue economy and resilient supply chains so that our region can continue to enjoy robust and durable growth.

**Samdech Thipadei** also took the opportunity to reaffirm Cambodia's supports for Timor-Leste to become a full member of ASEAN at the earliest and expressed support for any practical or creative approach to this end. **Samdech Thipadei** welcomed growing interest from countries outside the region to accede to the Treaty of Amity and Cooperation in Southeast Asia ( TAC ) and supported any partner who wants to form a relationship with ASEAN based on the principles of mutual respect, trust and benefit.

In the Retreat Session, the Leaders discussed the implementation of the Five-Point Consensus on Myanmar and exchanged views on regional and international issues of common interest and concern.

2. **ASEAN Leaders' Interfaces**

At the ASEAN Leaders' Interface with ASEAN Inter-Parliamentary Assembly (AIPA) Representatives, **Samdech Thipadei** emphasized the importance of promotingand maintaining the existing peace and peaceful coexistence among states at a time of resurgent violent conflicts in many parts of the world and the rising extremism and populism. **Samdech Thipadei** also stressed the need for governments and parliaments to strengthen cooperation to promote emerging industries — notably digital economy and green transition, and to put in place effective legal frameworks to help ASEAN tap into the great potentials that these sectors bring.

At the ASEAN Leaders' Interface with the ASEAN Business Advisory Council, **Samdech Thipadei** emphasized the importance of continued collaboration between public and private sectors to support infrastructure projects when fiscal space is limited and encouraged further cooperation in the areas of regional connectivity, digital transformation, and green transition. **Samdech Thipadei** informed the meeting that Cambodia has just unveiled the "Comprehensive Master Plan on Cambodia Intermodal Transport and Logistics System" in early 2024 and invited the private sector to consider this attractive opportunity. **Samdech Thipadei** also underscored the critical role of the private sector in contributing to rapid economic growth, and the improvement of the well-being of the people in the region.

Phnom Penh, 10 October 2024